# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តភ្នំពេញ

លេខ......១៥២០.........ក. ស. ភ.

ថ្ងៃច័ន្ទ ១០ រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២៤

# សេចក្តីលម្អិតព័ត៌មាន
## ស្តីពី
## ការជ្រើសរើសបុគ្គលិក

កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឲ្យបានជ្រាបថា ក. ស. ភ. ត្រូវការជ្រើសរើសបុគ្គលិកក្របខណ្ឌពេញសិទ្ធិ ក.ស.ភ. ចំនួន ៣៥រូប និងកម្មករសេរីចំនួន ៤រូប ដើម្បីបំពេញភារកិច្ចទទួលខុសត្រូវ និងបំពេញលក្ខខណ្ឌជ្រើសរើស ដូចខាងក្រោម៖

I. **នាយកដ្ឋានគណនេយ្យ** (ចំនួន ១រូប)

១. បុគ្គលិកផ្នែកគណនេយ្យ ចំនួន ១រូប

<u>ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)</u>

- **ការងារផ្នែកចំណូល៖**
  - ត្រួតពិនិត្យវិក្កយបត្រលក់ និងឯកសារយោងផ្សេងៗ
  - កត់ត្រាប្រតិបត្តិការលក់ និងសាច់ប្រាក់ដែលទទួលបានពីអតិថិជនទៅក្នុងប្រព័ន្ធគណនេយ្យ
  - រៀបចំសក្ខីបត្រចុះបញ្ជី និងទិន្នានុប្បវត្តិចំណូល
  - តាមដាននូវអាយុកាលគណនីត្រូវទទួល (Aging of Account Receivable) ជាប្រចាំនិងរៀបចំរបាយការណ៍
  - ផ្ទៀងផ្ទាត់លំហូរសាច់ប្រាក់ចូលជាមួយនឹងរបាយការណ៍ធនាគារ។
- **ការងារផ្នែកចំណាយ៖**
  - ត្រួតពិនិត្យវិក្កយបត្រទិញ និងឯកសារយោងផ្សេងៗ
  - រៀបចំសក្ខីបត្រចុះបញ្ជី និងទិន្នានុប្បវត្តិចំណាយ
  - កត់ត្រាប្រតិបត្តិការចំណាយ និងសាច់ប្រាក់ដែលទូទាត់ជូនអ្នកផ្គត់ផ្គង់ទៅក្នុងប្រព័ន្ធគណនេយ្យ
  - តាមដានអាយុកាលគណនីត្រូវទូទាត់ (Aging of Account Payable) ជាប្រចាំ
  - ផ្ទៀងផ្ទាត់លំហូរសាច់ប្រាក់ចេញជាមួយនឹងរបាយការណ៍ធនាគារ
  - កត់ត្រាការបញ្ចូល-បញ្ចេញសន្និធិគ្រឿងបន្លាស់ សម្ភារការិយាល័យ ប្រេងឥន្ធនៈ និងសន្និធិផ្សេងៗទៀតចូលក្នុងប្រព័ន្ធគណនេយ្យ
  - ផ្ទៀងផ្ទាត់នូវរបាយការណ៍ចំណាយ (ជាសាច់ប្រាក់) ជាមួយនឹងរបាយការណ៍បញ្ចូល-បញ្ចេញសន្និធិ (ចំនួន) ជាប្រចាំខែជាមួយបុគ្គលិកដែលទទួលបន្ទុកលើផ្នែកសន្និធិ
  - រៀបចំទិន្នានុប្បវត្តប្រចាំខែ (Monthly Journal)
- **ការងារផ្នែកទ្រព្យសកម្មរយៈពេលវែង (ចលនទ្រព្យ និងអចលនទ្រព្យ) ៖**
  - ត្រួតពិនិត្យ និងគ្រប់គ្រងរាល់ទ្រព្យសកម្មរយៈពេលវែង និងទ្រព្យសកម្មតូចតាចនៅតាមចំណតផែនានា

- កំណត់កូដភ្ជាប់រាល់ទ្រព្យសកម្មរយៈពេលវែងទាំងអស់ និងទ្រព្យសកម្មតូចតាច
- បញ្ចូលព័ត៌មានបន្ថែមរាល់ការទិញទ្រព្យសកម្មរយៈពេលវែង និងទ្រព្យសកម្មតូចតាចថ្មី
- រៀបចំទិន្នានុប្បវត្តិសម្រាប់ចំណាយរំលស់ និងធ្វើការកត់ត្រាចូលក្នុងប្រព័ន្ធគណនេយ្យ
- កំណត់ និងវាយតម្លៃរយៈពេលប្រើប្រាស់ទៅលើចំណាយដែលមានការកែលម្អ ឬជួសជុលច្រើនដង

• **ការងារផ្នែកសន្និធិសម្ភារការិយាល័យ និងគ្រឿងបន្លាស់៖**

- ត្រួតពិនិត្យ និងតាមដាននូវការបញ្ចូល-បញ្ចេញសន្និធិសម្ភារការិយាល័យ ជាប្រចាំនៅតាមចំណតផែនានា
- ត្រួតពិនិត្យ និងតាមដានការបញ្ចូល-បញ្ចេញគ្រឿងបន្លាស់ និងថែទាំគ្រឿងចក្រជាប្រចាំនៅតាមចំណតផែនានា
- រៀបចំរបាយការណ៍បញ្ចូល-បញ្ចេញសន្និធិសម្ភារការិយាល័យជាប្រចាំខែ នៅតាមចំណតផែនានា
- រៀបចំរបាយការណ៍បញ្ចូល-បញ្ចេញគ្រឿងបន្លាស់ និងថែទាំគ្រឿងចក្រ ជាប្រចាំខែនៅតាមចំណតផែនានា
- រៀបចំរបាយការណ៍លើសម្ភារការិយាល័យ និងគ្រឿងបន្លាស់ និងថែទាំគ្រឿងចក្រដែលមានគុណភាពថយចុះ និងពុំបានប្រើប្រាស់ជូន អនុប្រធានការិយាល័យទទួលបន្ទុក
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រងប្រគល់ជូន។

<u>*ខ. លក្ខខណ្ឌជ្រើសរើស* **(Job Requirements)**</u>

- មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ/ហិរញ្ញវត្ថុ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារយ៉ាងតិច ១ ឆ្នាំ ត្រូវបានផ្តល់អាទិភាព
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អលើការសរសេរ អាន ស្តាប់ និងនិយាយ
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រលើជំនាញគណនេយ្យ និងកម្មវិធីកុំព្យូទ័រ Ms. Word, Excel & Power Point
- មានចរិតស្លូតបូត សុភាពរាបសារ និងរួសរាយរាក់ទាក់
- មានឆន្ទៈក្នុងការអនុវត្តការងារខ្ពស់
- មានសមត្ថភាពដោះស្រាយបញ្ហា ទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់ និងអាចធ្វើដំណើរផ្លូវឆ្ងាយក្នុងករណីចាំបាច់។

II. **នាយកដ្ឋានគ្រប់គ្រងគ្រឿងចក្រ** បំពេញការងារនៅចំណតផែកុងតឺន័រ LM១៧ (ចំនួន ៣៤រូប)

**២. ផ្នែកបញ្ជាដងយោង RTG ចំនួន ១៨រូប**

<u>*ក. ភារកិច្ចទទួលខុសត្រូវ* **(Job Responsibilities)**</u>

- បញ្ជាដងយោង RTG សម្រាប់ការងារលើកដាក់កុងតឺន័រ
- បញ្ចូលទិន្នន័យកុងតឺន័រក្នុងប្រព័ន្ធ Resource Director Technology (RDT)
- ទទួលខុសត្រូវលើការចូលរួមសម្អាត ថែទាំ និងប្រើប្រាស់គ្រឿងចក្រទៅតាមបច្ចេកទេស និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់
- ទទួលអនុវត្តការងារផ្សេងៗទៀតដែលថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រងប្រគល់ជូន។

<u>*ខ. លក្ខខណ្ឌជ្រើសរើស* **(Job Requirements)**</u>

- មានកម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រផ្នែករដ្ឋបាល
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបាន
- មានជំនាញក្នុងការទំនាក់ទំនង សម្របសម្រួលនឹងអង្គភាពពាក់ព័ន្ធ

- មានគំនិតច្នៃប្រឌិតក្នុងការងារ និងមានសមត្ថភាពក្នុងការដោះស្រាយបញ្ហា
- អាចធ្វើការស្ថិតក្រោមបរិយាកាសដែលមានសម្ពាធដើម្បីសម្រេចការងារតាមកាលកំណត់
- មានឆន្ទៈក្នុងការបំពេញការងារជាក្រុម
- មានឆន្ទៈក្នុងការសិក្សាស្វែងយល់ និងអភិវឌ្ឍសមត្ថភាពដើម្បីបំពេញការងារប្រចាំថ្ងៃ
- មានទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់
- អាចធ្វើដំណើរទៅបំពេញការងារឆ្លងវេនឆ្ងាយក្នុងករណីចាំបាច់។

**៣.ផ្នែកបញ្ជាដងយោង FCC ចំនួន ២រូប**

**ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- បញ្ជារថយន្តកុងតឺន័រ FCC សម្រាប់ការងារលើកដាក់កុងតឺន័រ
- បញ្ចូលទិន្នន័យកុងតឺន័រក្នុងប្រព័ន្ធ Resource Director Technology (RDT)
- ទទួលខុសត្រូវលើការចូលរួមសម្អាត ថែទាំ និងប្រើប្រាស់គ្រឿងចក្រទៅតាមបច្ចេកទេស និងប្រកបដោយការ យកចិត្តទុកដាក់ខ្ពស់
- ទទួលអនុវត្តការងារផ្សេងៗទៀត ដែលថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រងប្រគល់ជូន។

**ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានកម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្ររងឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រផ្នែករដ្ឋបាល
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបាន
- មានជំនាញក្នុងការទំនាក់ទំនង សម្របសម្រួល និងអង្គភាពពាក់ព័ន្ធ
- មានគំនិតច្នៃប្រឌិតក្នុងការងារ និងមានសមត្ថភាពក្នុងការដោះស្រាយបញ្ហា
- អាចធ្វើការស្ថិតក្រោមបរិយាកាសដែលមានសម្ពាធដើម្បីសម្រេចការងារតាមកាលកំណត់
- មានឆន្ទៈក្នុងការបំពេញការងារជាក្រុម
- មានឆន្ទៈក្នុងការសិក្សាស្វែងយល់ និងអភិវឌ្ឍសមត្ថភាពដើម្បីបំពេញការងារប្រចាំថ្ងៃ
- មានទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់
- អាចធ្វើដំណើរទៅបំពេញការងារឆ្លងវេនឆ្ងាយក្នុងករណីចាំបាច់។

**៤. ផ្នែកបញ្ជារថយន្ត Reach-Stacker ចំនួន ៣រូប**

**ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- បញ្ជារថយន្ត (Reach-Stacker) លើកដាក់កុងតឺន័រក្នុងការផ្តល់សេវាកម្មរបស់ ក.ស.ភ.
- បញ្ចូលទិន្នន័យកុងតឺន័រក្នុងប្រព័ន្ធប្រតិបត្តិការ Terminal Operating System ( TOS )
- ទទួលខុសត្រូវលើការថែទាំប្រើប្រាស់គ្រឿងចក្រទៅតាមលក្ខណៈបច្ចេកទេស ដោយយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាបានសុវត្ថិភាព
- លាងសម្អាតគ្រឿងចក្រ ទៅតាមកាលវិភាគដែលបានកំណត់
- ទទួលអនុវត្តការងារផ្សេងៗទៀត ដែលថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រងប្រគល់ជូន។

**ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្ររងឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានប័ណ្ណបើកបរប្រភេទ "គ" "ឃ" ឬប្រភេទ "ង" ត្រូវបានផ្តល់អាទិភាព
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសកម្រិតមធ្យម
- ពុំធ្លាប់មានបទល្មើសនៃការបើកបរ

- មានជំនាញក្នុងការទំនាក់ទំនង សម្របសម្រួលនឹងអង្គភាពពាក់ព័ន្ធ
- មានគំនិតច្នៃប្រឌិតក្នុងការងារ និងមានសមត្ថភាពក្នុងការដោះស្រាយបញ្ហា
- អាចធ្វើការស្ថិតក្រោមបរិយាកាសដែលមានសម្ពាធដើម្បីសម្រេចការងារតាមកាលកំណត់
- មានឆន្ទៈក្នុងការបំពេញការងារជាក្រុម
- មានឆន្ទៈក្នុងការសិក្សាស្វែងយល់ និងអភិវឌ្ឍសមត្ថភាពដើម្បីបំពេញការងារប្រចាំថ្ងៃ
- មានទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់
- អាចធ្វើដំណើរទៅបំពេញការងារផ្លូវឆ្ងាយក្នុងករណីចាំបាច់។

**៥. ផ្នែកបញ្ជារថចូក E.V ចំនួន ២រូប**

**ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- បញ្ជារថចូក E.V សម្រាប់ការងារលើកដាក់កុងតឺន័រ និងទំនិញ
- បញ្ចូលទិន្នន័យកុងតឺន័រក្នុងប្រព័ន្ធ Resource Director Technology (RDT)
- ទទួលខុសត្រូវលើការចូលរួមសម្អាត ថែទាំ និងប្រើប្រាស់គ្រឿងចក្រទៅតាមបច្ចេកទេស និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់
- ទទួលអនុវត្តការងារផ្សេងៗទៀត ដែលថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រងប្រគល់ជូន។

**ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានកម្រិតវប្បធម៌ចាប់ពីកម្រិតមធ្យមសិក្សាទុតិយភូមិឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងតិច ១ឆ្នាំឡើងទៅ ត្រូវបានផ្តល់អាទិភាព
- មានសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រផ្នែករដ្ឋបាល
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបាន
- មានប័ណ្ណបើកបរប្រភេទ "ខ" ឡើងទៅ
- អាចធ្វើការស្ថិតក្រោមបរិយាកាសដែលមានសម្ពាធដើម្បីសម្រេចការងារតាមកាលកំណត់
- មានឆន្ទៈក្នុងការបំពេញការងារជាក្រុម
- មានឆន្ទៈក្នុងការសិក្សាស្វែងយល់ និងអភិវឌ្ឍសមត្ថភាពដើម្បីបំពេញការងារប្រចាំថ្ងៃ
- មានទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមាន ការអត់ធ្មត់ខ្ពស់
- អាចធ្វើដំណើរទៅបំពេញការងារផ្លូវឆ្ងាយក្នុងករណីចាំបាច់។

**៦. ផ្នែកបើកបររថយន្តសណ្តោង (រថយន្តដឹកកុងតឺន័រ) ចំនួន ៩រូប**

**ក. ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)**

- បើកបររថយន្តដឹកកុងតឺន័រសម្រាប់ការងារដឹកជញ្ជូនកុងតឺន័រ និងទំនិញ
- បញ្ចូលទិន្នន័យកុងតឺន័រក្នុងប្រព័ន្ធ Resource Director Technology (RDT)
- ទទួលខុសត្រូវលើការចូលរួមថែទាំ និងប្រើប្រាស់រថយន្តទៅតាមបច្ចេកទេស និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។
- លាងសម្អាតរថយន្តជាប្រចាំតាមកាលកំណត់
- ទទួលអនុវត្តការងារផ្សេងៗទៀត ដែលថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រងប្រគល់ជូន។

**ខ. លក្ខខណ្ឌជ្រើសរើស (Job Requirements)**

- មានសញ្ញាបត្រចាប់ពីកម្រិតមធ្យមសិក្សាទុតិយភូមិឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ផ្នែកបើកបរយ៉ាងតិច ១ ឆ្នាំឡើងទៅ
- មានប័ណ្ណបើកបរប្រភេទ "គ" "ឃ" ឬប្រភេទ "ង"
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសកម្រិតមធ្យម

- ពុំធ្លាប់មានបទល្មើសនៃការបើកបរ
- អាចធ្វើការស្ថិតក្រោមបរិយាកាសដែលមានសម្ពាធដើម្បីសម្រេចការងារតាមកាលកំណត់
- មានឆន្ទៈក្នុងការបំពេញការងារជាក្រុម
- មានឆន្ទៈក្នុងការសិក្សាស្វែងយល់ និងអភិវឌ្ឍសមត្ថភាពដើម្បីបំពេញការងារប្រចាំថ្ងៃ
- មានទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់
- អាចធ្វើដំណើរទៅបំពេញការងារផ្លូវឆ្ងាយក្នុងករណីចាំបាច់។

៦. កម្មករសេរី (ចំនួន ៤រូប)

ក. <u>ភារកិច្ចទទួលខុសត្រូវ (Job Responsibilities)</u>

- លាងសម្អាតទូកុងតឺន័រ
- ជួសជុលទូកុងតឺន័រ
- ទទួលអនុវត្តការងារផ្សេងៗទៀតតាមការចាត់ចែងរបស់ថ្នាក់លើ។

ខ. <u>លក្ខខណ្ឌជ្រើសរើស (Job Requirements)</u>

- មានសញ្ញាបត្រចាប់ពីកម្រិតមធ្យមសិក្សាបឋមភូមិឡើងទៅ ឬសញ្ញាបត្រមានតម្លៃស្មើ
- មានបទពិសោធន៍ការងារផ្នែកផ្សារ/តោន ត្រូវបានផ្តល់អាទិភាព
- ចេះអានអក្សរខ្មែរ
- អាចធ្វើការស្ថិតក្រោមបរិយាកាសដែលមានសម្ពាធដើម្បីសម្រេចការងារតាមកាលកំណត់
- មានឆន្ទៈក្នុងការបំពេញការងារជាក្រុម
- មានទំនាក់ទំនងល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានការអត់ធ្មត់ខ្ពស់
- អាចធ្វើដំណើរទៅបំពេញការងារផ្លូវឆ្ងាយក្នុងករណីចាំបាច់។

បើបេក្ខជន បេក្ខនារីមានចំណាប់អារម្មណ៍ សូមចូលរួមដាក់ពាក្យប្រលងប្រជែងចូលបម្រើការងារនៅ ក. ស. ភ. ដោយមានភ្ជាប់ជាមួយនូវប្រវត្តិរូបសង្ខេប (CV) និង Cover Letter ដោយមានបិទរូបថតថ្មីទំហំ ៤ x ៦ លិខិតបញ្ជាក់សញ្ញាបត្រ ឬការសិក្សា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ លិខិតបញ្ជាក់កំណើត (ឯកសារថតចម្លង) មកដាក់នៅទីស្នាក់ការកណ្តាលកំពង់ផែស្វយ័តភ្នំពេញ (ចំណតផែពហុបំណង TS៣) ដែលមានទីតាំងស្ថិតនៅ អគារលេខ ៦៤៩ បន្ទប់១១០ តីរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈអ៊ីម៉ែល ឬតេឡេក្រាម ដូចខាងក្រោម៖

អ៊ីម៉ែល : ppaphr.2022@gmail.com

តេឡេក្រាម : (០៩៣ ៤៤៤ ៥១៧)

លេខទូរស័ព្ទទំនាក់ទំនងផ្តល់ព័ត៌មាន: ០១០ ៤៤៤ ២៣៩/០១០ ៤៤៤ ០៥៨/០៩៣ ៤៤៤ ៥១៧។

**កាលបរិច្ឆេទឈប់ទទួលពាក្យ** : ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

**បញ្ជាក់:** - បេក្ខជនដែលជាប់ក្នុងបញ្ជីសម្រាំងជ្រើសរើស (Short-listed candidates) នឹងត្រូវបានជូនដំណឹងស្តីពីការចូលរួមប្រលងក្នុងទំព័រ Facebook របស់ ក. ស. ភ. (កំពង់ផែស្វយ័តភ្នំពេញ - Phnom Penh Autonomous Port)

- រាល់ឯកសារដែលបានដាក់ពាក្យរួចហើយរបស់បេក្ខជន មិនអាចដកវិញបានទេ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**ប្រធានអគ្គនាយក**

ហ៊ី-ប៊ុនវីរ